ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខៈ...១៤០...................សហអរ

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**តាមរយៈ:** លោកជំទាវរដ្ឋលេខាធិការ ទទួលបន្ទុក DICO
**កម្មវត្ថុ:** របាយការណ៍នៃកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោងលើកទី៣៤
**យោង:** - លិខិតអញ្ជើញរបស់ក្រសួងពាណិជ្ជកម្ម No.២៧១៣ ពណសហអ ចុះថ្ងៃទី៦ សីហា ២០១៤
- កម្មវិធីកិច្ចប្រជុំប្រចាំឆ្នាំ ២០១៤ របស់ Trade SWAp

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព ជម្រាបជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា: គណៈកម្មាធិការអនុវត្តគម្រោង IC (Implementation Committee) បានរៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួនកាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០១៤ វេលាម៉ោង ៨:៣០ ព្រឹក នៅក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីយភាព **លោកជំទាវ តឹករ៉េត កំរេង** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗ នៃកិច្ចប្រជុំខាងលើនេះ មានដូចខាងក្រោម ៖

## I. **របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ** TDSP

### ក). ការងារថវិកា:

- គិតចាប់ពីពេលអនុវត្តន៍គម្រោងដំបូង ពីឆ្នាំ ២០០៩ រហូតដល់ថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០១៤ នេះយើងបានធ្វើការចំណាយសរុបចំនួនតែ 57% នៃជំនួយសរុប គិតជាតួរលេខជាក់ស្តែងគឺ ចំនួន $8,814,083 នៃចំនួនមូលនិធិសរុប $15,450,000 ។
- ដោយបូករួមជាមួយថវិកាបន្ថែមចំនួន $3,100,000 នោះយើងមានថវិកាប្រមាណ $5,247,809 (34%) ដែលត្រូវចំណាយក្នុងរយៈពេល ៧ខែ ខាងមុខនេះ។ ចំណុចដែល យើងត្រូវយកចិត្ត

ទុកដាក់នោះគឺនៅត្រង់ថា យើងត្រូវចំណាយប្រហែល $700,000 ក្នុងមួយ ខែ ទើបយើងអាចប្រើប្រាស់អស់ថវិកាខាងលើ ។

- ថវិកាសម្រាប់ការប្រតិបត្តិការរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ (DICO) មានចំនួន 9% ដែលស្មើនឹង $1,388,108 ។

## ខ). ស្ថានភាពការអនុវត្តគម្រោង:

- ✓ ការចរចារកិច្ចសន្យាជាមួយក្រុមហ៊ុន CrimsonLogic (CL): ចំនួនថវិការសម្រាប់កិច្ចសន្យានេះ មានចំនួន $360,000 បូកនឹងប្រាក់សម្រាប់បង់ពន្ធចំនួន $51,900 ។ រាល់ឯកសារពាក់ព័ន្ធបានបញ្ជូនទៅធនាគារពិភពលោកកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ ដើម្បីផ្តល់ការយល់ព្រម លើកលែងតែពង្រៀងនៃកិច្ចសន្យាដែលកំពុងពិនិត្យដោយភាគីទាំងពីរ ។ យើងរំពឹងថាកិច្ចសន្យានឹងត្រូវបានចុះហត្ថលេខានៅអាទិត្យទី១ ខែកញ្ញា ឆ្នាំ២០១៤។
- ✓ គេហទំព័រព័ត៌មានពាណិជ្ជកម្ម (Trade Information Website-TIW): មាន Software ស្រាប់ដែលនឹងផ្តល់ដោយធនាគារពិភពលោក ហើយយើងគ្រាប់តែកែសម្រួលទៅតាមបរិបទរបស់ប្រទេសយើង។ យើងចាំបាច់ត្រូវបង្កើតអោយមានគណៈកម្មការជាតិមួយ ដែលមានអន្តរក្រសួងចូលរួម សម្រាប់ដឹកនាំការងារនេះ ដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកដឹកនាំ (Non-Tariff Measure and National Trade Repository Committee) ។ ចំណែកក្រសួងពាណិជ្ជកម្មវិញកំពុងរៀបចំប្រកាសស្តីពីការអនុវត្តគម្រោង TIW (Trade Information Website) ដោយជ្រើសរើសយកនាយកដ្ឋានស្ថិតិនិងព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មជាលេខាធិការដ្ឋាន ។
- ✓ ស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម (Business Registration Automation): រាល់ឯកសារគម្រោង ផែនការសកម្មភាព និងផែនការថវិកាត្រូវបានអនុម័តដោយ SSC។ ប៉ុន្តែ ToR នៅមិនទាន់បានផ្ញើរមក DICO ដើម្បីធ្វើលទ្ធកម្មនៅឡើយ។
- ✓ ស្វ័យប្រវត្តិកម្មវិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ (SPS Automation): រាល់ឯកសារគម្រោង ផែនការសកម្មភាព និងផែនការថវិកាត្រូវបានអនុម័តដោយ SSC។ ប៉ុន្តែ ToR នៅមិនទាន់បានផ្ញើរមក DICO ដើម្បីធ្វើលទ្ធកម្មនៅឡើយ។
- ✓ វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាណិជ្ជកម្ម TTRI (Trade Training and Research Institute): រាល់ឯកសារគម្រោង ផែនការសកម្មភាព និងផែនការថវិកាត្រូវបានអនុម័តដោយ SSC។ សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលលើកទី១ នឹងត្រូវរៀបចំឡើងនៅថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៤នេះ។ ToR ផ្សេងៗគឺចាំបាច់រៀបចំអោយបានឆាប់ផងដែរ។
- ✓ ការធ្វើលទ្ធកម្មទិញកំព្យូទ័រសម្រាប់នាយកដ្ឋានបុគ្គលិក: កិច្ចសន្យាបានចុះហត្ថលេខារួចហើយ។ កំព្យូទ័រទាំងអស់នឹងត្រូវផ្តល់មកក្រសួងពាណិជ្ជកម្ម ក្នុងកំឡុងពេល១ខែ ។

- ✓ ការធ្វើលទ្ធកម្មអ្នកផ្តល់សេវាបណ្តុះបណ្តាលភាសាអង់គ្លេស: កិច្ចសន្យាបានចុះហត្ថលេខារួចហើយ។ ពិធីសម្ពោធបើកវគ្គបណ្តុះបណ្តាលវគ្គទី១ នឹងមានការចូលរួមក្រោមអធិបតីភាព **ឯកឧត្តម ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។
- ✓ ការធ្វើលទ្ធកម្មទិញសម្ភារៈសម្រាប់នាយកដ្ឋានថ្មី: គណៈកម្មការលទ្ធកម្មកំពុងពិនិត្យមើល Specification ហើយការផ្សព្វផ្សាយទិញនឹងត្រូវធ្វើឡើងបន្ទាប់ពីមានការយល់ព្រមពីធនាគារពិភពលោក។

## II. **របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ** EIF

ក). គម្រោងពង្រឹងសមាហរណកម្មជំហ៊ានទី១ (EIF Tier 1, Phase I and II):

- ✓ ចាប់ផ្តើមខែ កុម្ភៈ ២០១០
- ✓ បញ្ចប់នៅខែ មិថុនា ២០១៥
- ✓ ថវិកាគម្រោងដំណាក់កាលទី១: $709,900
- ✓ ថវិកាគម្រោងដំណាក់កាលទី2: $584,000
- ✓ ថវិកាគម្រោងដំណាក់កាលទី1&2: $1,293,900
- ✓ សរុបថវិកាគម្រោងដែលទទួលបាន: $998,605
- ✓ សរុបថវិកាដែលបានចំណាយ: $918,736 ។ ក្នុងនោះសម្រាប់ឆ្នាំ២០១០ ចំណាយអស់ $12,844 ឆ្នាំ២០១១ចំណាយអស់ $192,991 ។ ឆ្នាំ២០១២ ចំណាយអស់ $313,290 ។ ឆ្នាំ ២០១៣ ចំណាយអស់ $284,826 និងរហូតមកដល់ខែមិថុនា ឆ្នាំ២០១៤នេះ គឺចំណាយអស់ $114,785 ។

ខ). គម្រោងពង្រឹងសមាហរណកម្មជំហានទី២ (EIF Tier 2):

- ✓ ចាប់ផ្តើមខែ កក្កដា ២០១២
- ✓ បញ្ចប់នៅខែ មិថុនា ២០១៥
- ✓ សរុបថវិកាគម្រោងដែលទទួលបាន: $75,000
- ✓ សរុបថវិកាដែលបានចំណាយ: $6,835 ។
- ✓ CEDEP I ផ្តោតលើវិស័យចំនួន ៣ គឺវិស័យអង្ករ (IFC) វិស័យសូត្រ (ITC) និងការត្រួតពិនិត្យ និងវាយតម្លៃ (DICO)។
- ✓ CEDEP II ផ្តោតលើវិស័យចំនួន ៣ គឺវិស័យដំឡូងមី (UNDP) ជលផល (UNIDO) រាជបណ្ឌិតសភាធ្វើម្ហូប ( Shift 360) និងការត្រួតពិនិត្យ និងវាយតម្លៃ (DICO)។
- ✓ នៅពេលអនាគត យើងនឹងអាចមានគម្រោង CEDEP III ដែលផ្តោតលើវិស័យមួយចំនួន ដូចជា វិស័យរោងចក្រធុនស្រាល វិស័យកៅស៊ូ វិស័យកែច្នៃផលិតផលកសិកម្ម។ល។

គ). សកម្មភាពរីកចម្រើនសំខាន់ៗរបស់គម្រោង:

- ✓ បានរៀបចំការប្រជុំប្រចាំឆ្នាំសម្រាប់ DICO នៅថ្ងៃទី០១-០២ ខែឧសភា ឆ្នាំ២០១៤
- ✓ បញ្ជូនមន្ត្រីក្រសួងពាណិជ្ជកម្មចំនួន ១៣ រូប ទៅបណ្តុះបណ្តាលភាសាអង់គ្លេសនៅ ACE
- ✓ រៀបចំកិច្ចប្រជុំមន្ត្រី LO និង Core Team ធ្វើឡើងនៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៤ ។
- ✓ បញ្ជូនមន្ត្រី ៤រូប ចូលរួមសិក្ខាសាលាស្តីពី ការត្រួតពិនិត្យវាយតម្លៃរបស់កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម និងការអភិវឌ្ឍសមត្ថភាពផ្នែកទំនាក់ទំនង (EIF Monitoring and Evaluation and Communication Capacity Development) នៅថ្ងៃទី១៩-២៣ ខែឧសភា ឆ្នាំ ២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ។ ក្នុងនោះមន្ត្រី៣រូប មកពីនាយកដ្ឋានសហ ប្រតិបត្តិការអន្តរជាតិ និង១រូបជាមន្ត្រី EIF Liaison Official មកពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
- ✓ បញ្ជូនមន្ត្រី៣រូបចូលរួមពិពណ៌ស្តីពី (THAIFEX–World Food of Asia 2014, Impact Exhibition Center) ចាប់ពីថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ។
- ✓ រៀបចំសម្របសម្រួលការសិក្សាស្រាវរបស់ក្រុមការងារ EIF និង WTO មកធ្វើការសិក្សាលើការវិភាគបញ្ហាពាក់ព័ន្ធអនាម័យ និងភូតគាមអនាម័យ។
- ✓ រៀបចំសិក្ខាសាលារួមគ្នាជាមួយក្រសួងទេសចរណ៍ស្តីពី (ជំនួយសម្រាប់ពាណិជ្ជកម្ម និងទេសចរណ៍ កម្ពុជា: ការវាយតម្លៃ និងទិសដៅ) ប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ នៅសណ្ឋាគារ ហ៊ីម៉ាវារី ក្រុងភ្នំពេញ ។
- ✓ ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព និងផែនការថវិកា សម្រាប់ Tier 1
- ✓ ធ្វើបច្ចុប្បន្នភាពផែនការថវិកា សម្រាប់ Tier 2
- ✓ បញ្ចប់ផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ ២០១៣-២០១៥។
- ✓ រៀបចំបោះពុម្ពផ្សាយប្រតិបត្តព័ត៌មានសម្រាប់ Trade SWAp ។
- ✓ រៀបចំផែនការសម្រាប់ការទំនាក់ទំនងផ្សព្វផ្សាយរួមគ្នាសម្រាប់ EIF និង TDSP។
- ✓ ធ្វើការជាមួយក្រុមបេសកកម្មរបស់ ES & TFM កាលពីថ្ងៃទី ១៤-១៨ ខែកក្កដា ឆ្នាំ២០១៤។ ព្រមទាំងបានទទួលអនុសាសន៍សម្រាប់ Tier1, CEDEP I, CEDEP II, និងការបង្កើតសាលារាជបណ្ឌិតសភាធ្វើម្ហូប (RACA)។
- ✓ ចុះហត្ថលេខាលើ MoU ចំនួន៦ កាលពីថ្ងៃទី ២៤ កក្កដា ឆ្នាំ២០១៤ ដោយមានការកែសម្រួលលើផែនការសកម្មភាព និងផែនការថវិកា។
- ✓ បានទទួលពង្រាង MoU របស់ CEDEP I ពី EIF-ES ហើយយើងបានពិនិត្យ និងដាក់ជូនថ្នាក់គ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មចុះហត្ថលេខា។

✓ បានទទួលពង្រាង MoU របស់ CEDEP II ពី EIF-ES ហើយយើងបានពិនិត្យ និងដាក់ជូនថ្នាក់គ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មចុះហត្ថលេខា។

✓ កំពុងដំណើរការចរចារ លើការជ្រើសរើសទីប្រឹក្សាសម្រាប់ធ្វើការវាយតម្លៃគម្រោងពាក់កណ្តាលអណត្តិ (Mid-Term Evaluation-MTE) ។

✓ កំពុងដំណើរការជ្រើសរើសអ្នកគ្រប់គ្រប់កម្មវិធី EIF ។ គណៈកម្មការលទ្ធកម្មបានឯកភាពជ្រើសរើសបេក្ខជន ហើយកំពុងដំណើរការចរចារកិច្ចសន្យា។

✓ ជ្រើសរើសទីប្រឹក្សាជាតិផ្នែកត្រួតពិនិត្យ និងវាយតម្លៃ បន្ទាប់ពី MoU របស់ CEDEP I ត្រូវបានចុះហត្ថលេខារួចរាល់។

## III. បទបង្ហាញពីស្ថានភាពគម្រោងទាំងពីររបស់វិទ្យាស្ថានស្តង់ដារកម្ពុជា (ISC)

✓ <u>គម្រោងទី១</u>: ពង្រឹងសមត្ថភាពដល់វិទ្យាស្ថានស្តង់ដារកម្ពុជា: គម្រោងនេះបានសម្រេចលទ្ធផលជាច្រើន ហើយសកម្មភាពដែលកំពុងអនុវត្តមានដូចជា ការពិនិត្យលើការបកប្រែជាភាសាខ្មែរនូវស្តង់ដារ និងសេចក្តីណែនាំចំនួន ១២ និងសៀវភៅតូចចំនួន ៦។ រៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន ២ និងការទិញសៀវភៅបច្ចេកទេស Software និង កាសែតវីដេអូបច្ចេកទេស។

✓ <u>គម្រោងទី២</u>: រៀបចំស្តង់ដារអង្គរជាតិ: គម្រោងនេះបានសម្រេច លទ្ធផលជាច្រើន ហើយសកម្មភាពដែលកំពុងអនុវត្តមានដូចជា ការពិនិត្យលើភាសារអង់គ្លេស និងបកប្រែជាភាសាខ្មែរនូវសៀវភៅតូចចំនួន ៦ ខិត្តប័ណ្ណចំនួន ២ និងការទិញសៀវភៅបច្ចេកទេស និងវិធីសាស្ត្រពិសោធន៍ AOAC។

✓ វិទ្យាស្ថានស្តង់ដារកម្ពុជាស្នើបន្តកិច្ចសន្យាអោយដល់ទីប្រឹក្សាជាតិសម្រាប់គម្រោងទី១ និងបន្តកិច្ចសន្យាដល់ទីប្រឹក្សាជាតិ និងអន្តរជាតិសម្រាប់គម្រោងទី២ ដើម្បីអោយពួកគាត់បញ្ចប់កិច្ចការដែលនៅសេសសល់ រួមទាំងពន្លឿនការជ្រើសរើសក្រុមហ៊ុន Accreditation System of Australia-New Zealand, JAS-ANZ (Accreditation Body)។

## IV. បទបង្ហាញរបស់សភាពាណិជ្ជកម្មកម្ពុជា

សភាពាណិជ្ជកម្មកម្ពុជា (CCC) បាននិងកំពុងអនុវត្តគម្រោងគាំទ្រវេទិការដ្ឋាភិបាល និងវិស័យឯកជន។ ដោយការចាប់ផ្តើមអនុវត្តគម្រោងមានការយឺតយ៉ាវ ព្រោះតែការជ្រើសរើសទីប្រឹក្សាអន្តរជាតិមានការយឺតយាវ គម្រោងក៏នៅមានការងារដែលត្រូវបន្តអនុវត្តមួយចំនួនដូចជា ការសិក្សាស្រាវជ្រាវចំនួនពីរស្តីពី ពន្ធដារ និងថាមពល ផលិតព្រឹត្តប័ត្រព័ត៌មាន រៀបចំគេហទំព័រ និងប្រព័ន្ធទិន្នន័យរៀបចំសិក្ខាសាលា ថ្នាក់ខេត្តចំនួន៦ និងសិក្ខាសាលាថ្នាក់ជាតិចំនួន១ ។ល។ លើសពីនេះទៀត គម្រោង

មើលឃើញនូវ កិច្ចចាំបាច់បន្ថែមចំនួនពីរទៀតដែលត្រូវអនុវត្តគឺ (១) ការរៀបចំក្របខ័ណ្ឌការងារសម្រាប់កិច្ចសន្ទនាថ្នាក់ខេត្តរវាងវិស័យសាធារណៈនិងឯកជន និង (២) បញ្ចូលនូវនីតិវិធីរួមបច្ចុប្បន្នកម្ម (Standard Operation Procedures - SOPs) ជាការនាំផ្លូវសម្រាប់ដំណើរការរបស់ក្រុម ការងារវិស័យឯកជន (PSWG) ។ អាស្រ័យដូចនេះ សភាពាណិជ្ជកម្មកម្ពុជា សូមស្នើ (១) សុំបន្តរយៈពេលអនុវត្តគម្រោងរហូតដល់ខែ មីនា ឆ្នាំ ២០១៥ ដោយពុំមានការកែប្រែនូវថវិកាគម្រោងនោះទេ និង(២) កែសម្រួលខ្ទង់ថវិកាមួយចំនួន (Budget lines) សម្រាប់សកម្មភាពគម្រោងដែលចាំបាច់ និងបន្តកិច្ចសន្យាទីប្រឹក្សា តែមិនត្រូវការថវិកាបន្ថែមនោះទេ។

➢ អង្គប្រជុំបានអនុម័តលើការស្នើនេះ។

## V. បទបង្ហាញរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បាននិងកំពុងអនុវត្តគម្រោងស្តីពីការអភិវឌ្ឍប្រព័ន្ធជាតិសម្រាប់ការបង្កើតកម្មសិទ្ធិបញ្ញា កិច្ចការពារ ការគ្រប់គ្រង និងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា (A Stronger National System for IP Generation, Protection, Administration and Enforcement)។

ដើម្បីអោយការងារផ្ទៀងផ្ទាត់នូវទិន្នន័យបញ្ជីឈ្មោះពាណិជ្ជកម្មមានដំណើរបានល្អ និងមិនមានភាពរអាក់រអួល នាយកដ្ឋានបានស្នើសុំថវិកាបន្ថែមចំនួន $២១,០០០ ដើម្បីទិញសម្ភារៈ និងតំឡើងប្រព័ន្ធសម្រាប់ពង្រឹងការងារផ្ទៀងផ្ទាត់ទិន្នន័យបញ្ជីឈ្មោះពាណិជ្ជកម្មនៅកម្ពុជា។

➢ អង្គប្រជុំបានអនុម័តលើគម្រោងស្នើនេះ។

## VI. អនុសាសន៍ និងការណែនាំរបស់លោកជំទាវ និងឯកឧត្តម រដ្ឋលេខាធិការ

ក្នុងនាមជាប្រធានគណៈកម្មការអនុវត្តគម្រោង លោកជំទាវ តឹកវ៉េត កំរង និងឯកឧត្តម ប៉ាន សូរស័ក្ត បានផ្តល់នូវ អនុសាសន៍ និងការណែនាំមួយចំនួនដូចខាងក្រោម:

- ✓ អបអរសាទរចំពោះលទ្ធផលដែលសម្រេចបានកន្លងមកក្នុងក្របខ័ណ្ឌ Trade SWAp, TDSP និង EIF ។
- ✓ ស្នើនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ពិភាក្សាជាមួយអ្នកពាក់ព័ន្ធលើលទ្ធភាពក្នុងការរៀបចំគម្រោងស្តង់ដារសម្រាប់ម្ហូបអាហារ "ហាឡាល" ។
- ✓ ស្នើនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា ធ្វើការពិភាក្សាជាមួយធនាគារពិភពលោក ក្នុងការជ្រើសរើសក្រុមហ៊ុន Accreditation System of Australia-New Zealand, JAS-ANZ (Accreditation Body) ដើម្បីអនុវត្តការងារអោយបានឆាប់។

- ✓ ស្នើឲ្យភ្នាក់ងារអនុវត្តគម្រោងទាំងអស់ ពិនិត្យមើលឡើងវិញនូវសកម្មភាពក្នុងគម្រោងរបស់ខ្លួន ថាតើសកម្មភាពណាដែលមិនអាចអនុវត្តទៅបានក្នុងរយៈពេលគម្រោង រួចធ្វើការកែសម្រួលថវិកាទាំងនោះសម្រាប់សកម្មភាពដែលជាអាទិភាព ហើយសូមមេត្តារួសរាន់លើកសំណើរមក DICO។

អាស្រ័យហេតុនេះសូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។
សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ សីហា ២០១៤

**ប្រធាននាយកដ្ឋាន**

ឈៀង ពេជ្រ

ចម្លងជូន:

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- គ្រប់សមាជិក SSC-TD-TRI
- គ្រប់សមាជិក IC
- ឯកសារ - កាលប្បវត្តិ

បានឃើញហើយ

គោរពជូន ឯកឧត្តម ទេសរដ្ឋមន្ត្រី

មេត្តាជ្រាបជារបាយការណ៍ និង

មានមតិស្រាស្រង់ដឹកនាំ ដ៏ខ្ពង់ខ្ពស់.

Khain

19/08/2014

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ២៧១៣ ក.ណ. សហ៤

ភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

## សូមគោរពជូន

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**កម្មវត្ថុ** ៖ សំណើសុំអញ្ជើញសមាជិកគណៈកម្មការអនុវត្តន៍គម្រោង (IC) ចូលរួមកិច្ចប្រជុំ IC លើកទី៣៤។

**ជូនភ្ជាប់** ៖ របៀបវារៈនៃកិច្ចប្រជុំ

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប ដើម្បីជំរុញការអនុវត្ត Trade SWAp ឲ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសមាជិកគណៈកម្មការអនុវត្តន៍គម្រោង (IC) មកចូលរួមកិច្ចប្រជុំ IC លើកទី ៣៤ របស់គណៈកម្មការអនុវត្តន៍គម្រោងប្រចាំខែសីហា។

កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង០៨:៣០នាទី នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្មក្រោមអធិបតីភាព **លោកជំទាវ តឹករ៉េត កំរេច** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តាមកម្មវិធីដូចមានចែងនៅក្នុងរបៀបវារៈជូនភ្ជាប់។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតឲ្យ ឯកឧត្តម តឹករ៉េត សំរេច ដែលជាអនុប្រធាននៃគណៈកម្មការអនុវត្តន៍គម្រោងមូលនិធិពហុភាគី ដើម្បីអញ្ជើញចូលរួមប្រជុំតាមកាលបរិច្ឆេទ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីនាងខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**តឹករ៉េត_កំរេច**

ចម្លងជូន:
-ឯកសារ-កាលប្បវត្តិ

ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ:
ទូរស័ព្ទ: ០១២-៤០៤-២៣០, ០១២-៨៧៦-៣២០
អ៊ីម៉ែល: manymamkh@yahoo.com, haoann2003@yahoo.com

# PROVISIONAL AGENDA

## The 34th Implementation Committee Meeting

August 14, 2014 at 8:30 A.M.

Venue: The Ministry of Commerce

| | | |
|---|---|---|
| 08:00-08:30 | • **Arrival of IC members** | |
| 08:30-08:40 | • **Welcome Remarks** | • H.E. PAN Sorasak, Secretary of State, MoC |
| 08:40-09:00 | • Progress of TDSP and EIF Implementation | • Mr. Chhieng Pich, Director, DICO |
| 09:00-09:30 | • Progress Updates by Implementing Agencies:<br>• Standard Development<br>• Support to G-PSF<br>• IPR | • Representatives of Relevant Implementing Agencies |
| 09:30-09:50 | • Other businesses | • All |
| 09:50-10:00 | • **Wrap-up and closing remarks** | • H.E. PAN Sorasak, Secretary of State, MoC |

***Note:*** *This provisional agenda is subject to change.*